ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)

លេខ ៣៣២០ ២១ គ.វ.ក-១៩

ថ្ងៃ ច័ន្ទ ១ រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២១

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសជំរុញ ឬដូសទី៣ ជូនដល់កុមារ និងយុវជន ដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់អាយុក្រោម ១៨ឆ្នាំ

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា គ.វ.ក-១៩ នឹងផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ដោយប្រើប្រាស់វ៉ាក់សាំងស៊ីណូវ៉ាក់ ជូនដល់កុមារ និងយុវវ័យ ដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់អាយុក្រោម ១៨ឆ្នាំ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ រួចរាល់ ហើយមានគម្លាតចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ ដោយអនុវត្តនូវ *យុទ្ធសាស្ត្រផ្ការីក* របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលនឹងចាប់ផ្តើមចេញពីរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រះសីហនុ ខេត្តកោះកុង ចាប់ពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ រួចបន្តទៅខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ចាម និងខេត្តស្វាយរៀង ចាប់ពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ និងនៅតាមបណ្តាខេត្តផ្សេងៗជាបន្តបន្ទាប់ទៀត ដូចមានរៀបរាប់ខាងក្រោម៖

**ក. កាលបរិច្ឆេទ នៃយុទ្ធនាការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសជំរុញ ឬដូសទី៣ ជូនដល់ក្រុមគោលដៅ ៖**

យោងតាមកាលបរិច្ឆេទ នៃការបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋាន ជូនដល់កុមារ និងយុវវ័យ មានអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ និងដើម្បីឱ្យមានគម្លាតចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ គ.វ.ក-១៩ បានរៀបចំកាលបរិច្ឆេទ នៃការចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ដូសជំរុញ ឬដូសទី៣ ជូនដល់ក្រុមគោលដៅនេះ នៅទូទាំង២៥រាជធានី-ខេត្ត ដូចខាងក្រោម៖

<table>
<tr><th>ល.រ</th><th>រាជធានី/ខេត្ត</th><th>កាលបរិច្ឆេទចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងដូសជំរុញ ឬដូសទី៣</th></tr>
<tr><td>១</td><td>ភ្នំពេញ</td><td rowspan="4">ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២</td></tr>
<tr><td>២</td><td>កណ្តាល</td></tr>
<tr><td>៣</td><td>ព្រះសីហនុ</td></tr>
<tr><td>៤</td><td>កោះកុង</td></tr>
<tr><td>៥</td><td>កំពង់ស្ពឺ</td><td rowspan="4">ថ្ងៃទី១០ ខែមករា ឆ្នាំ២០២២</td></tr>
<tr><td>៦</td><td>តាកែវ</td></tr>
<tr><td>៧</td><td>កំពង់ចាម</td></tr>
<tr><td>៨</td><td>ស្វាយរៀង</td></tr>
</table>



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

Scanned with SwiftScan

| | | |
|---|---|---|
| ៩ | ត្បូងឃ្មុំ | ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ |
| ១០ | ប៉ៃលិន | |
| ១១ | កែប | |
| ១២ | រតនៈគិរី | |
| ១៣ | បាត់ដំបង | ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ |
| ១៤ | កំពង់ឆ្នាំង | |
| ១៥ | ពោធិ៍សាត់ | |
| ១៦ | សៀមរាប | |
| ១៧ | ឧត្តរមានជ័យ | |
| ១៨ | កំពង់ធំ | ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២ |
| ១៩ | ព្រះវិហារ | ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ |
| ២០ | មណ្ឌលគិរី | |
| ២១ | ក្រចេះ | ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ |
| ២២ | ព្រៃវែង | |
| ២៣ | បន្ទាយមានជ័យ | ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ |
| ២៤ | កំពត | |
| ២៥ | ស្ទឹងត្រែង | ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ |

**ខ. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ជូនដល់កូនចៅមន្ត្រីរាជការថ្នាក់ជាតិ ៖**

ចំពោះកូនចៅរបស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ថ្នាក់ជាតិ ដែលមានអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ ហើយបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២ រួចរាល់ និងមានគម្លាតចាប់ពី៤ខែឡើង សូមអញ្ជើញទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ចាប់ពីថ្ងៃទី០៣ ខែមករា ឆ្នាំ២០២២ នៅតាមមន្ទីរពេទ្យជាតិនានា ដែលមានទីតាំង កាលបរិច្ឆេទ និងពេលវេលាដូចខាងក្រោម៖

១. មន្ទីរពេទ្យកាល់ម៉ែត និងមន្ទីរពេទ្យព្រះអង្គឌួង៖

- ចំពោះកូនចៅថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា ថ្នាក់ដឹកនាំរដ្ឋសភា និងសមាជិករដ្ឋសភា និងកូនចៅឥស្សរជនដែលមានតួនាទី ជាឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ នៅមន្ទីរពេទ្យកាល់ម៉ែត។
- ចំពោះកូនចៅឥស្សរជនដែលជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬមានឋានៈស្មើ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ នៅមន្ទីរពេទ្យព្រះអង្គឌួង។

ការចាក់វ៉ាក់សាំងកូវីដ-១៩ ស៊ីណូវ៉ាក់ដូសជំរុញ ឬដូសទី៣ ជូនដល់ក្រុមគោលដៅខាងលើ នឹងត្រូវរៀបចំតាមពេលវេលា និងកាលបរិច្ឆេទ ដូចខាងក្រោម៖

| លរ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ០៣ ដល់ ០៥ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងព្រះបរមរាជវាំង | | |
| ៣ | -ព្រឹទ្ធសភា | | |
| ៤ | -ទីស្តីការគណៈរដ្ឋមន្ត្រី | | |
| ៥ | -រដ្ឋសភា | | |



Scanned with SwiftScan

| | | | |
|---|---|---|---|
| ៦ | -ក្រសួងសុខាភិបាល | ០៦ ដល់ ០៩ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រុមប្រឹក្សាធម្មនុញ្ញ | | |
| ៨ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ៩ | -ក្រសួងអប់រំ យុវជន និងកីឡា | | |
| ១០ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | |
| ១១ | -ក្រសួងព័ត៌មាន | | |
| ១២ | -តុលាការកំពូល | | |
| ១៣ | -សាលាឧទ្ធរណ៍ភ្នំពេញ | | |
| ១៤ | -ធនាគារជាតិ នៃកម្ពុជា | | |
| ១៥ | -ក្រសួងមហាផ្ទៃ | ១០ ដល់ ១៣ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៦ | -ក្រសួងការពារជាតិ | | |
| ១៧ | -ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | | |
| ១៨ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |
| ១៩ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | |
| ២០ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |
| ២១ | -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) | | |
| ២២ | -ក្រសួងផែនការ | | |
| ២៣ | -ក្រសួងអភិវឌ្ឍន៍ជនបទ | ១៤ ដល់ ១៧ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២៤ | -អាជ្ញាធរសេវនកម្មជាតិ | | |
| ២៥ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |
| ២៦ | -ក្រសួងសាធារណការ និងដឹកជញ្ជូន | | |
| ២៧ | -ក្រសួងបរិស្ថាន | | |
| ២៨ | -អង្គភាពប្រឆាំងអំពើពុករលួយ | | |
| ២៩ | -ក្រសួងកិច្ចការនារី | | |
| ៣០ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | |
| ៣១ | -ក្រសួងពាណិជ្ជកម្ម | | |
| ៣២ | -ក្រសួងមុខងារសាធារណៈ | | |
| ៣៣ | -កាកបាទក្រហមកម្ពុជា | | |
| ៣៤ | -ក្រសួងទេសចរណ៍ | ១៨ ដល់ ២១ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៣៥ | -ក្រសួងធម្មការ និងសាសនា | | |
| ៣៦ | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | |
| ៣៧ | -ក្រសួងធនធានទឹក និងឧតុនិយម | | |
| ៣៨ | -ក្រសួងយុត្តិធម៌ | | |
| ៣៩ | -គណៈមេធាវី | | |
| ៤០ | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | |
| ៤១ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | |



Scanned with SwiftScan

| | | | |
|---|---|---|---|
| ៤២ | -ក្រសួងរ៉ែ និងថាមពល | ២២ ដល់ ២៥ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៤៣ | -អគ្គិសនីកម្ពុជា | | |
| ៤៤ | -អាជ្ញាធរប្រេងកាត | | |
| ៤៥ | -អាកាសចរស៊ីវិល | | |
| ៤៦ | -អាជ្ញាធរផ្សេងៗ | | |

## ២. មន្ទីរពេទ្យកុមារជាតិ៖

មន្ទីរពេទ្យកុមារជាតិ ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ស៊ីណូវ៉ាក់ដូសជំរុញ ឬដូសទី៣ ជូនដល់កូនចៅមន្ត្រីរាជការ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិនៃក្រសួង-ស្ថាប័នចំនួន១៣ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងសុខាភិបាល | ០៣ ដល់ ០៨ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងមហាផ្ទៃ | | |
| ៣ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ៤ | -ធនាគារជាតិ នៃកម្ពុជា | | |
| ៥ | -ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ០៩ ដល់ ១៤ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៦ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | |
| ៧ | -ក្រសួងអប់រំ យុវជន និងកីឡា | | |
| ៨ | -ក្រសួងមុខងារសាធារណៈ | | |
| ៩ | -កាកបាទក្រហមកម្ពុជា | | |
| ១០ | -ក្រសួងសាធារណការ និងដឹកជញ្ជូន | ១៥ ដល់ ២២ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១១ | -ក្រសួងកិច្ចការនារី | | |
| ១២ | -ក្រសួងទេសចរណ៍ | | |
| ១៣ | -ក្រសួងព័ត៌មាន | | |

## ៣. មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក៖

មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ស៊ីណូវ៉ាក់ដូសជំរុញ ឬដូសទី៣ ជូនដល់កូនចៅមន្ត្រីរាជការ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ នៃក្រសួង-ស្ថាប័នចំនួន១៧ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម | ០៣ ដល់ ០៨ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងព្រះបរមរាជវាំង | | |
| ៣ | -ព្រឹទ្ធសភា | | |
| ៤ | -ក្រុមប្រឹក្សាធម្មនុញ្ញ | | |
| ៥ | -រដ្ឋសភា | | |
| ៦ | -ក្រសួងការពារជាតិ | ០៩ ដល់ ១៣ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៧ | -ក្រសួងយុត្តិធម៌ | | |
| ៨ | -គណៈមេធាវី | | |
| ៩ | -ក្រសួងផែនការ | | |





Scanned with SwiftScan

| | | | |
|---|---|---|---|
| ១០ | -ទីស្តីការគណៈរដ្ឋមន្ត្រី | ១៤ ដល់ ១៧ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១១ | -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | |
| ១២ | -តុលាការកំពូល | | |
| ១៣ | -សាលាឧទ្ធរណ៍ភ្នំពេញ | | |
| ១៤ | -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១៨ ដល់ ២២ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៥ | -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | |
| ១៦ | -អង្គភាពប្រឆាំងអំពើពុករលួយ | | |
| ១៧ | -គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) | | |

៤. មន្ទីរពេទ្យគន្ធបុប្ផា៖

មន្ទីរពេទ្យគន្ធបុប្ផាជាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ស៊ីណូវ៉ាក់ ដូសជំរុញ ឬដូសទី៣ ជូនដល់កូនចៅមន្ត្រីរាជការ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យាថ្នាក់ជាតិ នៃក្រសួង-ស្ថាប័នចំនួន១៦ ដូចមានក្នុងតារាងខាងក្រោម៖

| លរ | ឈ្មោះក្រសួង និងស្ថាប័ន | កាលបរិច្ឆេទ | ពេលវេលា |
|---|---|---|---|
| ១ | -ក្រសួងពាណិជ្ជកម្ម | ០៣ ដល់ ០៨ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ២ | -ក្រសួងធម្មការ និងសាសនា | | |
| ៣ | -ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | |
| ៤ | -ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | |
| ៥ | -ក្រសួងធនធានទឹក និងឧតុនិយម | ០៩ ដល់ ១៣ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ៦ | -ក្រសួងរ៉ែ និងថាមពល | | |
| ៧ | -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | |
| ៨ | -ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | |
| ៩ | -អគ្គិសនីកម្ពុជា | ១៤ ដល់ ១៨ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១០ | -អាជ្ញាធរប្រេងកាត | | |
| ១១ | -អាកាសចរស៊ីវិល | | |
| ១២ | -អាជ្ញាធរផ្សេងៗ | | |
| ១៣ | -ក្រសួងអភិវឌ្ឍន៍ជនបទ | ១៩ ដល់ ២២ មករា ២០២២ | ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០ |
| ១៤ | -អាជ្ញាធរសេវនកម្មជាតិ | | |
| ១៥ | -ក្រសួងបរិស្ថាន | | |
| ១៦ | -ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | |

**គ. ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ជូនដល់កូនចៅមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិក ស្ថានទូតនានា មន្ត្រី និងបុគ្គលិកអង្គការជាតិ អន្តរជាតិ អ្នកឧកញ៉ា លោកឧកញ៉ា និងឧកញ៉ា៖**

ចំពោះកូនចៅមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី បុគ្គលិកស្ថានទូត ស្ថានកុងស៊ុល ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា មន្ត្រី បុគ្គលិកអង្គការជាតិ អន្តរជាតិ និងដៃគូផ្សេងៗទៀត កូនចៅអ្នកឧកញ៉ា លោកឧកញ៉ា និងឧកញ៉ា សូមអញ្ជើញទៅទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ នៅ មន្ទីរពេទ្យកាល់ម៉ែត តាមពេលវេលា និងកាលបរិច្ឆេទដូចមានក្នុងតារាងខាងក្រោម៖



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរសព្ទ-ទូរសារ៖ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

Scanned with SwiftScan

<table>
<tr><th>ល.រ</th><th>ឈ្មោះអង្គភាព</th><th>កាលបរិច្ឆេទ</th><th>ពេលវេលា</th></tr>
<tr><td>១</td><td>-កូនចៅមន្ត្រីអង្គការសហប្រជាជាតិ មន្ត្រី និងបុគ្គលិកស្ថានទូត ស្ថានកុងស៊ុល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា</td><td rowspan="3">២៦ ដល់ ២៨ មករា ២០២២</td><td rowspan="3">ម៉ោង០៨:០០ ដល់១១:០០<br>ម៉ោង១៤:០០ ដល់១៧:០០</td></tr>
<tr><td>២</td><td>-កូនចៅមន្ត្រី និងបុគ្គលិកអង្គការជាតិ អន្តរជាតិ និងដៃគូផ្សេងៗទៀត</td></tr>
<tr><td>៣</td><td>-កូនចៅអ្នកឧកញ៉ា លោកឧកញ៉ា និងឧកញ៉ា</td></tr>
</table>

**ឃ. ការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ ដូសជំរុញ ឬដូសទី៣ ជូនដល់កូនចៅមន្ត្រីរាជការ និងកូនចៅប្រជាពលរដ្ឋក្រោមឱវាទរដ្ឋបាលរាជធានី-ខេត្តទាំង២៥ ៖**

ចំពោះកូនចៅមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា ព្រមទាំងកូនចៅប្រជាពលរដ្ឋទូទៅ ក្រោមឱវាទរដ្ឋបាលរាជធានី-ខេត្តទាំង២៥ នឹងត្រូវរៀបចំចាក់ជូនដោយរដ្ឋបាលរាជធានី-ខេត្តទាំង២៥ ដែលគ្រប់រដ្ឋបាលរាជធានី-ខេត្តទាំង២៥ នឹងចេញសេចក្តីជូនព័ត៌មានផ្សព្វផ្សាយជូនសាធារណជនជ្រាបពីទីតាំង នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ជូនដល់កុមារ និងយុវវ័យមានអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួច ហើយមានគម្លាតរយៈពេលចាប់ពី៤ខែឡើងបន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ ដោយចាប់ផ្តើមពីកាលបរិច្ឆេទដែលមានចែងក្នុងចំណុច «ក» ខាងលើ ។

**ង. ឯកសារត្រូវភ្ជាប់ជាមួយនៅពេលទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣៖**

ចំពោះគ្រប់កុមារ និងយុវវ័យ ដែលមានអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ ដែលត្រូវទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ត្រូវភ្ជាប់មកជាមួយនូវ ឯកសារមួយចំនួនដូចខាងក្រោម៖

- ប័ណ្ណ (កាត) ចាក់វ៉ាក់សាំងកូវីដ-១៩
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ឯកសារដែលប្រើប្រាស់ក្នុងការចុះឈ្មោះចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១
- និងប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ ឬប័ណ្ណសំគាល់មន្ត្រីជាប់កិច្ចសន្យា របស់ឪពុកម្តាយ (ចំពោះកូនចៅមន្ត្រីរាជការថ្នាក់ជាតិ)។

**ច. កិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរមូលដ្ឋាន ៖**

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត ត្រូវធ្វើសេចក្តីជូនព័ត៌មានស្តីពីការបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ជូនកុមារ និងយុវវ័យមានអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ ដោយមានភ្ជាប់ជាមួយនូវកាលបរិច្ឆេទ ពេលវេលា និងទីតាំងត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ និងត្រូវចាត់ចែងរៀបចំការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ជូនដល់កុមារ ដែលមកចាក់វ៉ាក់សាំងទាំងអស់ឱ្យមានភាពរលូន និងគ្រប់គ្រងសណ្តាប់ធ្នាប់ ព្រមទាំងអនុវត្តវិធានការសុខាភិបាល **ពាក់ម៉ាស់ រក្សាគម្លាតសុវត្ថិភាពចាប់ពី១,៥ម៉ែត្រឡើង លាងដៃញឹកញាប់** ដើម្បីការពារការចម្លងវីរុសកូវីដ-១៩ នៅតាមទីតាំងចាក់វ៉ាក់សាំងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ គ.វ.ក-១៩ សូមអំពាវនាវដល់ លោកអ៊ុំ ពូ មីង ពុក ម៉ែ បងប្អូនទាំងអស់ សូមមេត្តាចូលរួម ដោយនាំកូនចៅ ចៅទួត កូន ក្មួយ ដែលមានអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី១ និងដូសទី២រួច ហើយមានគម្លាតរយៈពេលចាប់ពី៤ខែឡើង បន្ទាប់ពីការចាក់វ៉ាក់សាំងដូសទី២ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ នៅតាមទីតាំង តាមកាលបរិច្ឆេទដែលបានកំណត់ឱ្យបានគ្រប់គ្នា ដើម្បីបង្កើនភាពស៊ាំទប់ទល់នឹងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសបំប្លែងខ្លួនថ្មីប្រភេទដែលតា និងវីរុសបំប្លែងខ្លួនថ្មីប្រភេទអូមីក្រុងដែលកំពុងចរាចរយ៉ាងសកម្មនាពេលបច្ចុប្បន្ននេះ។

ទន្ទឹមគ្នានេះដែរ គ.វ.ក-១៩ សូមគោរពជម្រាបជូនផងដែរថា ទោះបីជាបុគ្គលម្នាក់ៗបានទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ រួចរាល់ហើយក្តី ក៏ត្រូវបន្តអនុវត្តនូវវិធានការ «៣ការពារ» (ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពី





Scanned with SwiftScan

មួយម៉ែត្រកន្លះឡើងទៅ) និង «៣កុំ» (កុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក៏ដូចជាបន្តរួមគ្នាអនុវត្តតាមយុទ្ធនាការជាតិអប់រំក្រោមប្រធានបទ *«រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩»* ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងសហគមន៍ នៃប្រទេសកម្ពុជា និងរក្សានិរន្តរភាព នៃការរស់នៅធម្មតា តាមប្រក្រតីភាពថ្មីក្នុងបរិបទនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ជូនកុមារ និងយុវវ័យមានអាយុចាប់ពី១២ឆ្នាំ ដល់អាយុក្រោម១៨ឆ្នាំ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោមនៅរៀងរាល់ម៉ោងធ្វើការ៖

ក-ក្រុមការងារទំនាក់ទំនងសាធារណ: / លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០៨៩ ៩៨០ ៦៦៦ | ០១០ ២៣៣ ៥៨៨ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៤៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.ជ.ក-១៩**

**វេជ្ជបណ្ឌិត ឱ វណ្ណឌីន**





Scanned with SwiftScan